ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩៣១ ចុះថ្ងៃទី ២១
ខែ វិច្ឆិកា ឆ្នាំ ២០០៥
សាលក្រម
លេខ ៣៧ ក ចុះថ្ងៃទី ១៧
ខែ កុម្ភៈ ឆ្នាំ ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៩៣១ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ ឈ ឈ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីជាងសំណង់ មានទីកន្លែងកំណើតនៅភូមិគោកពន្លៃ ឃុំអូរម៉ាល់ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី៧ កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិគីឡូលេខ ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ **ភ ន** (រ) មានកូន ០៣នាក់ មានឪពុកឈ្មោះ **ជ ឈ** (ស) មានម្តាយឈ្មោះ **ង ឈ** (រ) ទោសពីមុន *គ្មាន* ។

ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំណុចផ្ទះជនជាប់ចោទ ភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងពន្ធនាគារខេត្តបាត់ដំបង តាមដីកាឃុំខ្លួន លេខ ៥៧៤ ដឃខ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

ត្រូវចាប់ខ្លួនពីបទ **សំរួលដោយចេតនាអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន** និង ប្រើប្រាស់គ្រឿងញៀនហាមឃាត់ខុសច្បាប់ តាមបញ្ញត្តិមាត្រា៣៥ថ្មី ៥៨ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំណុចផ្ទះឈ្មោះ ឈ ឈ ស្ថិតក្នុងភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង បានបើកកន្លែងសំរួលអោយ

អ្នកដទៃប្រើប្រាស់គ្រឿងញៀនបង្កដោយឈ្មោះ **ឈ ឈ** បានផ្ដល់ឧបករណ៍ប្រើប្រាស់អោយអ្នកដទៃជក់គ្រឿងញៀនដើម្បីយកឈ្នួល ។ មិនតែប៉ុណ្ណោះឈ្មោះ **ឈ ឈ** ក៏បានប្រើប្រាស់គ្រឿងញៀនផ្ទាល់ខ្លួនផងដែរ ។

តាមដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ១៣១ ពស.ព្រទ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបអង្កេតបានសំរេចចោទប្រកាន់លើឈ្មោះ **ឈ ឈ** ពីបទសំរួលដោយចេតនាអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀន ប្រព្រឹត្តនៅភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ មកជំនុំជំរះតាមច្បាប់ ។

## នៅចំពោះមុខតុលាការពេលសវនាការ

ឈ្មោះ **ឈ ឈ** ជាជនជាប់ចោទបានឆ្លើយបញ្ជាក់ថា ខ្ញុំបាទត្រូវសមត្ថកិច្ចចាប់ខ្លួន កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំរេះភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន មូលហេតុខ្ញុំប្រើប្រាស់គ្រឿងញៀន និង ផ្ដល់កន្លែង អោយគេប្រើប្រាស់គ្រឿងញៀន ។ ខ្ញុំចេះជក់គ្រឿងញៀនតាំងពីឆ្នាំ ២០០០ ជាមធ្យមខ្ញុំជក់ក្នុងមួយថ្ងៃ ០១គ្រាប់ ទៅ ០២គ្រាប់ ប្រដាប់ជក់មានបំពង់ជ័រដាក់ទឹកបំពង់បឺត និង កន្ទោងសំរាប់ដុតថ្នាំញៀន ។ អ្នកជក់នៅផ្ទះខ្ញុំ១ចាំមិនអស់ទេ គេទិញថ្នាំមកជក់នៅផ្ទះខ្ញុំ ដោយខ្ញុំមានប្រដាប់ជក់ក្នុងមួយថ្ងៃមានអ្នកមកជក់ម្នាក់ ឬ ០២នាក់ គេអោយកំរៃ ១០បាត ទៅ ២០បាត ជូនគេអោយថ្នាំជក់ ។

## តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឈ ឈ ពីបទសំរួលដោយចេតនាអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រា៣៥ថ្មី,៩៨ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និង សុំអោយតុលាការផ្ដន្ទាទោសកំណត់ពី ០១ឆ្នាំ ដល់ ០៣ឆ្នាំ និង ០១ខែ ។

ឈ្មោះ ឈ ឈ សុំតុលាការមេត្តាបន្ធូរបន្ថយទោស ។

-បានស្ដាប់ចម្លើយដោះសាររបស់ជនជាប់ចោទ
-បានពិនិត្យ កំណត់ហេតុ ឯកសារ ភស្តុតាងនានា
-បានស្ដាប់សេចក្ដីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ
-បានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបង
## យល់ឃើញថា

-ពិតជាកើតមាននូវអំពើសំរួលអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀន ដោយខុសច្បាប់នៅភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើសំរួលអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ ដែលមាន

កន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ ឈ ឈ បានសំរួលទីកន្លែង និង ប្រដាប់ប្រដាឱ្យដល់អ្នកដទៃប្រើប្រាស់គ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀននៅនឹងផ្ទះរបស់ខ្លួនពិតប្រាកដមែន ។

-អំពើដែលឈ្មោះ ឈ ឈ បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់ជាបទសំរួលអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀន ដូចមានបញ្ញត្តិក្នុងមាត្រា ៣៥.២ថ្មី និង ៩៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទជាសមត្ថជនគាត់មានអាយុ ៤០ឆ្នាំ មានស្មារតីជាទាល្អ គាត់បានប្រព្រឹត្តអំពើដោយចេតនានូវអំពើល្មើសដូចការចោទប្រកាន់ ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ឈ ឈ ពីបទ សម្រួលអោយអ្នកដទៃប្រើប្រាស់គ្រឿងញៀន និង បទប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់ស្ថាប័នអយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយដោះសាររបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់យ៉ាងច្បាស់អំពីអំពើដែលខ្លួនបានប្រព្រឹត្តវាស៊ីសង្វាក់គ្នាទៅនឹងវត្ថុតាងមានឧបករណ៍ប្រើប្រាស់សំរាប់ជក់ថ្នាំញៀន ដែលរឹបអូសបានពីជនជាប់ចោទ និង ហេតុការណ៍កាលៈទេសៈនៃបទល្មើស ។

-វត្ថុតាងមានបំពង់សំរាប់បឺតថ្នាំជក់ចំនួន ១០ដបភ្ជាប់បំពង់សំរាប់ជក់ថ្នាំញៀនចំនួន ០២កន្ទោងក្រដាសបារីសំរាប់ជក់ថ្នាំញៀនចំនួន ៨ ដែលនគរបាលយុត្តិធម៌រឹបអូសបានពីលំនៅដ្ឋានជនជាប់ចោទ ជាករណីជាបទល្មើសជាក់ស្តែង ។

-កំណត់ហេតុ ឯកសារភស្តុតាងនានាធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

## យល់ឃើញថា

-ជនជាប់ចោទមានកិរិតវប្បធម៌ទាប គាត់មានជីវភាពក្រខ្សត់ គាត់ជាជនមិនធ្លាប់មានទោសពីមុនមកស្ថាន ទាំងនេះអាចអោយតុលាការយកមកពិចារណាជាស្ថានសម្រាលទោសអោយគាត់បាន ។

-វត្ថុតាងមាន ត្រូវរឹបអូសរួចបំផ្លាញចោល ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ ឈ ឈ ដាក់ពន្ធនាគារកំណត់ :

-០១ឆ្នាំគត់ ពីបទសម្រួលដោយចេតនាអោយអ្នកដទៃប្រើប្រាស់ ដោយខុសច្បាប់នូវគ្រឿងញៀន ។

-០១ខែគត់ពីបទ ប្រើប្រាស់គ្រឿងញៀនដោយខុសច្បាប់ ។

ទណ្ឌកម្មសរុបកំណត់០១ឆ្នាំ និង ០១ខែ គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ប្រព្រឹត្តនៅភូមិគីឡូលេខ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៣៥,២ថ្មី និង មាត្រា ៩៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៥០៥ /០១៤ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥ ។

២-វត្ថុតាងមានបំពង់សំរាប់បឺតថ្នាំញៀនចំនួន ១០ ដបភ្ជាប់សំរាប់ជក់ថ្នាំញៀនចំនួន ០២ និង កន្ទោងក្រដាសបារីសំរាប់ជក់ថ្នាំញៀនចំនួន ០៨ ត្រូវរឹបអូសរួចបំផ្លាញចោល ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តច្បាប់ សាលក្រមអោយសំរេចតាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្តអោយបានសំរេច បើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*

**ជ.ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]